# កិច្ចពិភាក្សា និង ចែករំលែកបទពិសោធន៍អំពី
# ការស្វែងរកអាហារូបករណ៍នៅសហរដ្ឋអាមេរិក ក្រៅពីកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាល

## សេចក្តីសង្ខេប

**មជ្ឈមណ្ឌលខេមរសិក្សា** (CKS) បានអញ្ជើញវាគ្មិន ២ រូប ដែលជាអតីតនិស្សិតចូលរួមកម្មវិធី Junior Resident Fellows Program និងទើបបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យល្បីៗចំនួន២ នៅសហរដ្ឋអាមេរិក គឺ Pittsburgh និង Standford ដើម្បីចែករំលែកពីរឿងរ៉ាវនៃដំណើរសិក្សារបស់ពួកគេចាប់ផ្តើម ពីប្រទេសកម្ពុជារហូតទៅដល់ សហរដ្ឋអាមេរិក តាមរយៈកម្មវិធីអាហារូបករណ៍ ដែលមិនមែនជាកម្មវិធីអាហារូបករណ៍ផ្តល់ដោយរដ្ឋាភិបាល ដែលយើងតែងធ្លាប់បានដឹងកន្លងមក។ ពួកគាត់ នឹងចែករំលែកផងដែរ នូវវិធីស្វែងរក និងការរៀបចំដាក់ស្នើសុំអាហារូបករណ៍។ ជាចុងក្រោយ អ្នកចូលរួម នឹងបានយល់ដឹងបន្ថែម អំពីបញ្ហាប្រឈមដែលពួកគាត់បានជួបប្រទះ ទាំងរាយកាយ និងស្មារតី នៅពេលកំពុងរស់នៅ និងសិក្សានៅទីនោះ ក្នុងអំឡុងពេលនៃការរាតត្បាត ជំងឺកូវីដ១៩ និងវិធីសាស្ត្រដើម្បីដោះស្រាយបញ្ហាទាំងនោះផងដែរ។

## ប្រវត្តិរូបសង្ខេប

### វាគ្មិន៖

**លោក អាន អាយយូរណាន់** បច្ចុប្បន្នមានអាយុ ២៤ឆ្នាំ ជានិស្សិតត្រៀមថ្នាក់បណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ (Public Policy) នាខែកញ្ញាខាងមុខនេះនៅសាកលវិទ្យាល័យ Toronto ប្រទេសកាណាដា។ គាត់បានបញ្ចប់ការសិក្សាផ្នែកអភិវឌ្ឍន៍អន្តរជាតិ (International Development) នៅសាលាកិច្ចការសាធារណៈនិងអន្តរជាតិ (GSPIA) នៃសាកលវិទ្យាល័យ Pittsburgh កាលពីខែឧសភា ឆ្នាំ២០២១ និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិនៅសាកលវិទ្យាល័យ Northern Illinois ក្នុងឆ្នាំ២០១៨ នៅសហរដ្ឋអាមេរិក។ នៅសាកលវិទ្យាល័យ Pittsburgh គាត់ជានិស្សិតអាហារូបករណ៍ H.J. Heinz Fellowship និងជានិស្សិតស្រាវជ្រាវក្នុងកម្មវិធីសមភាពយែនឌ័រក្នុងរដ្ឋបាលសាធារណៈ (GEPA) របស់អង្គការសហប្រជាជាតិ UNDP។ នៅឆ្នាំ២០១៨ គាត់ជានិស្សិតកម្មវិធី Junior Resident Fellow Program រៀបចំដោយមជ្ឈមណ្ឌលខេមរសិក្សា។ គាត់បានទទួលបទពិសោធន៍ការងារភាគច្រើនជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យការអភិវឌ្ឍ ការងារលើកកម្ពស់

សមភាពយេនឌ័រ ការលើកស្ទួយ និងការរីកចម្រើនរបស់សង្គមជាតិ និង វិស័យបដិវត្តឧស្សាហកម្ម ៤.០។

**កញ្ញា លេន សៀវឡាន** បច្ចុប្បន្នជានិស្សិតឆ្នាំទី២ ថ្នាក់អនុបណ្ឌិត ជំនាញគោលនយោបាយអន្តរជាតិ (International policy) ឯកទេសខាងអភិបាលកិច្ច និងការអភិវឌ្ឍ (Governance and Development) នៅសាកលវិទ្យាល័យ ស្តែនហ្វត (Stanford) ក្រោមការឧបត្ថមពី អាហារូបករណ៍ ណៃហិនន័រស៊ី (Knight-Hennessy)។ កញ្ញាក៏ជាបុគ្គលិកនិស្សិតស្រាវជ្រាវ នៃមជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិក (APARC) នៅស្តែនហ្វតផងដែរ។ មុនពេលមកបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅ សហរដ្ឋអាមេរិក សៀវឡាន បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែក កិច្ចការសាកល (Global Affairs)ពីសាកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ (AUPP)។ កញ្ញាក៏ជាអតីតនិស្សិត មូលនិធិហាប់ស្វែល (The Harpswell Foundation) ជាទីដែលកញ្ញាចាត់ទុកថាជាផ្ទះទី២ផងដែរ។ ក្រៅពីនេះ កញ្ញាក៏ធ្លាប់បានផ្លាស់ប្តូរបទពិសោធន៍សិក្សាចំនួនពីរលើក ទៅសាកលវិទ្យាល័យអាមេរិកកាំង (AU) នៅរដ្ឋធានីឌីស៊ី របស់សហរដ្ឋអាមេរិក តាមរយៈអាហារូបករណ៍ យូក្រាត (UGRAD) និងនៅសាកលវិទ្យាល័យ អាកនីសស្តត់(ASC) រដ្ឋចរចានៃសហរដ្ឋអាមេរិក។ សៀវឡាន មានបទពិសោធន៍ ស្រាវជ្រាវផ្នែក ចំណាកស្រុក គោលនយោបាយបរទេស យុទ្ធសាស្រ្តថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ក្នុងការអភិវឌ្ឍធនជានមនុស្ស។ កញ្ញាបានហាត់ការជាមួយមូលដ្ឋានខន់សលធិង(Moulathan Consulting) និង មូលនិធិខុនរ៉ាត (Konrad-Adenauer-Stiftung)។ សៀវឡាន ក៏ជានិស្សិតកម្មវិធី Junior Resident Fellow Program រៀបចំដោយមជ្ឈមណ្ឌលខេមរសិក្សាផងដែរ។

**អ្នកសម្របសម្រួល៖ កញ្ញា ស៊្វីង សាមុីឌី** ប្រធានកម្មវិធី នៃមជ្ឈមណ្ឌលខេមរសិក្សា។